# កិច្ចប្រជុំប្រចាំឆ្នាំ លើកទី៣២

ក្រោមប្រធានបទ

## ភាពជាដៃគូសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ក្រោយពីផលប៉ះពាល់នៃជំងឺកូវីដ១៩

**ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២** (ម៉ោង ៨:៣០ ព្រឹក ដល់ ៤:៣០ រសៀល)

សម្រាប់ការចូលរួមដោយផ្ទាល់ នៅសណ្ឋាគារ កាំបូឌីយ៉ាណា រាជធានីភ្នំពេញ

សម្រាប់ការចូលរួមអនឡាញ (ហ្សូម) តាមតំណភ្ជាប់ https://zoom.us/j/97405229048

## ១- សេចក្តីផ្តើម

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ជាអង្គការសមាជិកភាពឈានមុខគេ ដែលមានសមាជិកទាំងអង្គការជាតិ និងអង្គការបរទេសនៅកម្ពុជា ហើយបានដើរតួនាទីយ៉ាងសំខាន់ ចាប់តាំងពីឆ្នាំ១៩៩០។ អង្គការ គ.ស.ក មានតួនាទី និងធ្វើកិច្ចការយ៉ាងសកម្មជាងបីទស្សវត្សរ៍ ក្នុងនាមជាអ្នកសម្របសម្រួលឲ្យមានការរួបរួមគ្នា ដើម្បីបង្កបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល អភិបាលកិច្ចស្ថាប័ន និងគណនេយ្យភាពក្នុងការធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាព នៃដំណើរអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងប្រកបដោយចីរភាពនៅកម្ពុជា។ ក្នុងដំណាក់កាលបច្ចុប្បន្ន នៃកម្មវិធីមជ្ឈមណ្ឌលអភិបាលកិច្ច (GHP ២០២១-២០២៣)ដំណាក់កាលទីបួន ក្រោមទស្សនៈវិស័យ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងប្រជាធិបតេយ្យសម្រាប់ប្រទេសកម្ពុជា ហើយមានគោលដៅធំពីរៈ ១) ការលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល និង២) ការបំពេញមុខងារប្រកបដោយនិរន្តរភាព នៃមជ្ឈមណ្ឌលធនធានសម្រាប់សង្គមស៊ីវិលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ដើម្បីអបអរសាទរនូវតួនាទីយ៉ាងសំខាន់នេះ ជាពិសេសក្នុងការសម្របសម្រួល និងគាំទ្រ សម្រាប់អង្គការសមាជិកភាព និងភាពជាដៃគូ កិច្ចប្រជុំប្រចាំឆ្នាំនឹងត្រូវរៀបចំឡើង ជាព្រឹត្តិការណ៍ចម្បងសម្រាប់សមាជិកភាព ដៃគូ និងតួអង្គអភិវឌ្ឍសំខាន់ៗ ដើម្បីចែករំលែក ពិភាក្សា និងស្វែងរកការឆ្លើយតបសមស្រប សម្រាប់សកម្មភាពបន្ត។ ស្របតាមលក្ខន្តិកៈ កិច្ចប្រជុំប្រចាំឆ្នាំនេះ នឹងត្រូវបានធ្វើឡើង ដើម្បីពិនិត្យឡើងវិញនូវការងារកន្លងមក ព្រមទាំងពិភាក្សា និងរៀនសូត្រសម្រាប់ផែនការការងារឆ្នាំបន្ត។ សម្រាប់កម្មវិធីនេះ នឹងប្រារព្ធឡើងតាមបែបកូនកាត់ ***នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២*** ដែលវគ្គពេលព្រឹកផ្តោតលើប្រធានបទ **ភាពជាដៃគូសម្រាប់ការអភិវឌ្ឍ ប្រកបដោយនិរន្តរភាព ក្រោយពីផលប៉ះពាល់នៃជំងឺកូវីដ១៩** និងវគ្គពេលរសៀលផ្តោតលើការពិភាក្សា ជាពិសេសលើប្រធានបទស្នូល សំខាន់ៗពាក់ព័ន្ធការលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិល យុវជន និងអាស៊ាន។

អ្នកចូលរួមប្រមាណជាង ២០០ នាក់ មកពីអង្គភាពផ្សេងៗ ដែលជាអង្គការសមាជិកអង្គការ គ.ស.ក ដៃគូសង្គមស៊ីវិល និងភ្នាក់ងារអភិវឌ្ឍន៍ផ្សេងៗ *(តំណាងមន្ត្រីរដ្ឋាភិបាល ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ តំណាងស្ថាប័នផ្សេងៗ រួមទាំងវិស័យឯកជន)* តំណាងអង្គការសហគមន៍មូលដ្ឋាន និងក្រុមយុវជន ជាដើម នឹងត្រូវបានអញ្ជើញចូលរួម ជាភ្ញៀវកិត្តិយស ។

## ២- គោលបំណង

- ឆ្លុះបញ្ចាំងពីសកម្មភាពការងារឆ្នាំកន្លងទៅ និងអបអរសមិទ្ធផលសម្រេចបាន ព្រមទាំងការថ្លែងអំណរគុណសម្រាប់សមាជិក និងដៃគូ ពីការចូលរួមចំណែកក្នុងការអភិវឌ្ឍនៅកម្ពុជា
- ទទួលស្គាល់នូវការចូលរួមគាំទ្ររបស់អង្គការសមាជិកភាព និងដៃគូ និងការពិភាក្សាលើបញ្ហាសំខាន់ៗក្នុងការលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិល យុវជន និងអាស៊ាន
- ធ្វើអោយប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការ សម្រាប់អង្គការសមាជិកភាព ដៃគូម្ចាស់ជំនួយ បណ្តាញសម្របសម្រួលអង្គការខេត្ត ដៃគូអភិវឌ្ឍផ្សេងៗ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក្នុងការឆ្លើយតបបញ្ហាផ្សេងៗនៃការអភិវឌ្ឍ ក្នុងស្ថានភាពនៃជំងឺកូវីដ១៩។

## ៣- របៀបវារៈ

| ម៉ោង | ប្រធានបទ | វាគ្មិន |
|---|---|---|
| | **វគ្គពេលព្រឹក៖**<br>ភាពជាដៃគូសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ក្រៅពីផលប៉ះពាល់នៃជំងឺកូវីដ១៩ | |
| ៨:៣០ – ៩:០០ | **ការចូលរួមតាមអនឡាញ និងទំនាក់ទំនង** | អង្គការ គ.ស.ក និង អ្នកចូលរួម |
| ៩:០០ | • **ការប្រកាសកម្មវិធី និងគោរពភ្លេងជាតិ** | អ្នកកាន់កម្មវិធី៖ **អ្នកស្រី ប្រាក់ កែវគង្គា**<br>**លោក ជា វិបុល** |
| ៩:០៥ | • **របាំជូនពរ** | អង្គការសមាជិក |
| ៩:១០ – ១០:០០ | **សុន្ទរកថាស្វាគមន៍ ខ្លឹមសារគន្លឹះ និងបើកកម្មវិធី**<br>• **សុន្ទរកថាស្វាគមន៍**<br>• **ខ្លឹមសាគន្លឹះពីដៃគូអភិវឌ្ឍន៍**<br>• **សារគន្លឹះចាប់អារម្មណ៍ និងបើកកម្មវិធី** | ▪ **អ្នកស្រី ជី សុជាតិ** ប្រធានគណៈកម្មាធិការប្រតិបត្តិ និងជានាយិកាប្រចាំប្រទេស អង្គការ PSI<br>▪ **លោក Fabrizio Senesi** អ្នកសម្របសម្រួលគម្រោងអភិបាលកិច្ច និងសិទ្ធិមនុស្ស របស់សហគមន៍អឺរ៉ុបប្រចាំកម្ពុជា<br>▪ **ឯកឧត្តម ឈឹម កាន** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលទទួលបន្ទុកជាប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ នៃក្រសួងមហាផ្ទៃ |
| ១០:០០– ១០:១៥ | **សម្រាកថតរូប ទស្សនារូបថតអង្គការសមាជិក និងកសាងបណ្តាញទំនាក់ទំនង** | អ្នកចូលរួមទាំងអស់ |
| ១០:១៥ – ១០:៣៥ | **ប្រកាសជាផ្លូវការ៖ គណៈកម្មាធិការប្រតិបត្តិថ្មី ២០២២-២០២៣**<br>• សារគន្លឹះពីមេរៀនសំខាន់ៗរបស់គណៈកម្មាធិការប្រតិបត្តិ ចប់អាណត្តិ សម្រាប់ការងារជាមួយអង្គការសមាជិកភាព<br>• ចំណាប់អារម្មណ៍ ការតាំងចិត្ត និងសារគន្លឹះជាយុទ្ធសាស្រ្តការងារជាមួយអង្គការសមាជិក ពីគណៈកម្មាធិការប្រតិបត្តិថ្មី | **លោក ច័ន្ទ ភក្តី**<br>ប្រធានប្រតិបត្តិការ និងអភិវឌ្ឍន៍សមាជិកភាព អង្គការ គ.ស.ក |

| ម៉ោង | ប្រធានបទ | វាគ្មិន |
|---|---|---|
| ១០:៣៥–១០:៥៥ | <u>គន្លឹះសំខាន់ៗ</u>៖ **សមិទ្ធិផលសំខាន់ៗ របស់ គ.ស.ក សម្រាប់ ឆ្នាំ២០២១ និងផែនការប្រតិបត្តិសម្រាប់ ឆ្នាំ២០២២**<br>• វីដេអូខ្លីពីសមិទ្ធិផលសំខាន់ៗ សម្រាប់ឆ្នាំ២០២១<br>• វីដេអូខ្លី ស្តីពីការបង្ហាញគន្លឹះសំខាន់ៗនៃផែនការ ប្រតិបត្តិ សម្រាប់ឆ្នាំ២០២២<br><br>**សំណួរ និងចម្លើយ** | **អ្នកស្រី លុយ ធារី**<br>ប្រធានកម្មវិធី អង្គការ គ.ស.ក |
| ១០:៥៥–១១:៥៥ | <u>វេទិកាពិភាក្សារួម</u>៖ **ភាពជាដៃគូសម្រាប់ការអភិវឌ្ឍប្រកប ដោយនិរន្តរភាព ក្រោយពីផលប៉ះពាល់នៃជំងឺកូវីដ១៩ (ចក្ខុវិស័យ លើការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច)**<br><br>• តួនាទីសំខាន់ៗ របស់រដ្ឋាភិបាល  សង្គមស៊ីវិល និង វិស័យឯកជន ក្នុងការលើកកម្ពស់ការអភិវឌ្ឍសង្គម និង សេដ្ឋកិច្ច<br>• តើរដ្ឋាភិបាល  សង្គមស៊ីវិល និងវិស័យឯកជន គួរយក ចិត្តទុកដាក់សំខាន់ៗអ្វីខ្លះ សម្រាប់លើកកម្ពស់ការ អភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ក្រោយពីឥទ្ធិពលនៃជំងឺ កូវីដ១៩?<br>• តើមានយន្តការចាត់ចែងថវិកាសំខាន់ៗអ្វីខ្លះ ដែលអាច ផ្តល់អាទិភាពសម្រាប់ការអភិវឌ្ឍសង្គម និងសង្គម ស៊ីវិល?<br><br>**សំណួរ និងយោបល់ផ្សេងៗ** | **ដឹកនាំការពិភាក្សា៖ អ្នកស្រី ស៊ិន ពុទ្ធារី** នាយិកាប្រតិបត្តិ អង្គការ គ.ស.ក<br>**គណៈវាគ្មិន៖**<br>- **ឯកឧត្តម ហួត ពុំ** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ   និងជាអគ្គលេខាធិការរង អគ្គលេខា ធិការដ្ឋាន នៃគណៈកម្មាធិការគោលនយោបាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- **អ្នកស្រី Chikako Kodama,** ប្រធានទីប្រឹក្សាបច្ចេក ទេស ផ្នែកអភិបាលកិច្ច នៃគម្រោងអភិវឌ្ឍន៍អង្គការ សហប្រជាជាតិ<br>- **លោក Christian Kapfensteiner** ប្រធានកម្មវិធី ទីភ្នាក់ងារអាឡឺម៉ង់ សម្រាប់ការអភិវឌ្ឍអន្តរជាតិ<br>- **អ្នកស្រី   Kristen Rasmussen,** អ្នកសម្របសម្រួល អង្គការបរទេស និងជានាយិកាប្រចាំប្រទេស អង្គការ ជំនួយព្រះវិហារដាណឺម៉ាក |
| ១១:៥៥– ១២:០០ | **សរុបខ្លឹមសារ និងបន្តកម្មវិធីទៅ ពេលរសៀល** | ▪ **លោក កេង ប៊ុនឈឿត** គណៈកម្មាធិការប្រតិបត្តិ  និង ជានាយកប្រចាំតំបន់ អាស៊ីអាគ្នេយ៍ អង្គការ ERIKS<br>▪ **អ្នកកាន់កម្មវិធី** |
| ១២:០០– ១៣:៣០ | **ពិសារអាហារសាមគ្គីថ្ងៃត្រង់ និងកសាងបណ្តាញ ទំនាក់ទំនង** | **អ្នកចូលរួមទាំងអស់** |

| វគ្គពេលរសៀល៖<br>ការពិភាក្សាសំខាន់ៗលើប្រធានបទស្នូល បរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិល យុវជន និងអាស៊ាន | | |
|---|---|---|
| ១៣:៣០– ១៤:៥៥ | <u>វគ្គដែកពិភាក្សាតាមប្រធានបទ (បន្ទប់ ១)</u>៖ **សិទ្ធិឌីជីថល និងសេរីភាពអ៊ីនធើណិត**<br>(សម្រាប់ចូលរួមអនឡាញ តាមតំណភ្ជាប់ https://zoom.us/j/96088977824 )<br>• ដឹកនាំការពិភាក្សាដោយ៖ លោក **ផាន ភ័ព្វបារមី** ប្រធានកម្មវិធីជាន់ខ្ពស់ វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ<br>• វាគ្មិនកិត្តិយស៖<br>- **លោក ហ៊ឹម ខទៀត** មន្ត្រីគ្រប់គ្រងកម្មវិធីស្រាវជ្រាវ និងតស៊ូតមតិ ខេមបូចា<br>- **កញ្ញា សរ ពិសី** មន្ត្រីទំនាក់ទំនង អង្គការអាក់សិនអេតកម្ពុជា<br>- **លោក អ៊ិត សូធឿត** ប្រធាននាយកដ្ឋានប្រព័ន្ធផ្សព្វផ្សាយ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ<br>**សំណួរ & ចម្លើយ និងយោបល់ចូលរួម** | |
| | <u>វគ្គដែកពិភាក្សាតាមប្រធានបទ (បន្ទប់ ២)</u>៖ **ពន្ធដារ និងការអនុលោមតាមបទដ្ឋានគតិយុត្តិ សម្រាប់អង្គការមិនរកប្រាក់កម្រៃ** (សម្រាប់ចូលរួមអនឡាញ តាមតំណភ្ជាប់ **https://zoom.us/j/97405229048** )<br>• ដឹកនាំការពិភាក្សាដោយ៖ **អ្នកស្រី ស៊ិន ពុទ្ធារី** នាយិកាប្រតិបត្តិ អង្គការ គ.ស.ក<br>• វាគ្មិនកិត្តិយស៖<br>- **លោក ឈី ឆដាភា** ប្រធានអនុលោមច្បាប់ អង្គការ អាយឌីអ៊ី កម្ពុជា<br>- **លោក ស៊ុន ឡុង** នាយកប្រតិបត្តិការជាន់ខ្ពស់ អង្គការតម្លាភាព កម្ពុជា<br>- **លោក មាស យាង** ប្រធាននាយកដ្ឋានប្រតិបត្តិការ មជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ<br>- **លោក រឿន ប៊ុនហេង** ប្រធាននាយកប្រតិបត្តិ និងដៃគូ គណនេយ្យ និងពន្ធដារ ក្រុមហ៊ុន វីចធ៍ &ផាតនើរ<br>**សំណួរ & ចម្លើយ និងយោបល់ចូលរួម** | |
| ១៤:៥៥– ១៥:១០ | **សម្រាក និងកសាងបណ្តាញទំនាក់ទំនង** | |
| ១៥:១០– ១៥:៣០ | <u>ការសម្តែងសិល្បៈ ដោយអង្គការសមាជិក</u>៖<br>. សិល្បៈទស្សនីយភាព (របាំសហសម័យ) ដោយអង្គការអេពិកអាត | |
| ១៥:៣០– ១៦:១០ | <u>ការពិភាក្សារួមពេញអង្គ</u>៖ **ការចូលរួមរបស់យុវជន និងអាស៊ាន**<br>• ដឹកនាំការពិភាក្សាដោយ៖<br>- **អ្នកស្រី ចាន់ រ៉ាមី** នាយិកាប្រតិបត្តិ អង្គការ កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន<br>- **អ្នកស្រី អេង ចាន់ឌី** នាយិកាប្រតិបត្តិ អង្គការ យេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា<br>- **អ្នកស្រី សេង រាសី** នាយិកាប្រតិបត្តិ អង្គការ សីលការ<br>• អ្នកចូលរួមជាសមាជិក គ.ស.ក និងដៃគូនៅថ្នាក់ក្រោមជាតិ<br>**សំណួរ & ចម្លើយ និងយោបល់ចូលរួម** | |
| ១៦:១០– ១៦:២០ | **ការបង្ហាញរូបថតអង្គការសមាជិក និងការជូនរង្វាន់** | **លោក អ៊ុន សុធា និងលោក លឹម ឌីណា** |
| ១៦:២០– ១៦:៣០ | **សរុបខ្លឹមសារ និងបិទកម្មវិធី** | **អ្នកស្រី Sandra Veloso** អនុប្រធានគណៈកម្មាធិការប្រតិបត្តិ និងជានាយិកាប្រចាំតំបន់អាស៊ី អង្គការ AFSC |

***ចំណាំ៖*** *ក្នុងនាមអ្នករៀបចំ សូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធីអាស្រ័យលើករណីចាំបាច់របស់វាគ្មិន និងពេលវេលា។ កម្មវិធីនេះ មានបកប្រែជាភាសាអង់គ្លេស-ខ្មែរ។ សូមជម្រាបជូនជ្រាបថា៖ សកម្មភាព និងខ្លឹមសារសំខាន់ៗមួយចំនួនរបស់អ្នកចូលរួម នឹងត្រូវបានដកស្រង់ និងចែករំលែកតាមប្រព័ន្ធផ្សព្វផ្សាយដូចជា គេហទំព័រ និងបណ្តាញព័ត៌មានសង្គម។ http://www.ccc-cambodia.org/en/resources/event-archives www.facebook.com/CCCsince1990 www.youtube.com/CCCambodia*